**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលារាជធានីភ្នំពេញ**

លេខៈ ៤៦៣ លស.[illegible].២

*រាជធានីភ្នំពេញ ,ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣*

**<u>ជម្រាបមក</u>**

**លោក អភិបាលខណ្ឌទាំង ៩**

**<u>កម្មវត្ថុ:</u>** ស្តីពីការប្រមូលទុនចូលរួមរបស់មូលដ្ឋាន នៃគម្រោងមូលនិធិអភិវឌ្ឍន៍សង្កាត់។

**<u>យោង</u>** - សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ចុះថ្ងៃទី១៩ខែមករា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

-លិខិតលេខ២៨៦លស.ផរ.មជចុះថ្ងៃទី១២ខែសីហាឆ្នាំ២០១៣របស់សាលាខណ្ឌមានជ័យ

-ស្មារតីអង្គប្រជុំគណៈអភិបាលរាជធានីភ្នំពេញ នៅថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០១៣។

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមកលោកអភិបាលខណ្ឌជ្រាបថា: ផ្អែកតាមគោលការណ៍ណែនាំក្នុងសៀវភៅណែនាំ ស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ទុនចូលរួម របស់មូលដ្ឋាន គឺជាការចូលរួមចំណែកដោយស្ម័គ្រចិត្ត ការកំណត់ចំនួនទុនចូលរួមសរុប ត្រូវសម្រេចដោយក្រុមប្រឹក្សាសង្កាត់ហើយការប្រមូលទុនចូលរួមត្រូវអនុវត្តនៅក្នុងឆ្នាំថវិកា។

ការប្រមូលទុនចូលរួមនេះ ប្រជាពលរដ្ឋមូលដ្ឋានអាចចូលរួម ជាថវិកា ឬ ចូលរួមចំណែកដោយកំលាំងពលកម្ម ចំពោះអ្នកគ្មានលទ្ធភាពពិតប្រាកដមិនត្រូវបង្ខំជាដាច់ខាត។ ដូចនេះ លិខិតលេខ១៣២លស.គប្រ.ក្រមជ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៧ របស់សាលារាជធានីភ្នំពេញ ដែលបានកំណត់ការចូលរួមបដិភាគ ១០% របស់ប្រជាពលរដ្ឋ ត្រូវបាននិរាករណ៍ចាប់ពីពេលនេះតទៅ។

ម្យ៉ាងទៀតបើសិនមានការចូលរួមជួយឧបត្ថម្ភពីសប្បុរសជន សាលាខណ្ឌទាំង៩ ត្រូវរៀបចំចេញលិខិតថ្លែងអំណរគុណ ឱ្យបានត្រឹមត្រូវ និងមានតម្លាភាព។

ដូច្នេះការប្រមូលទុនចូលរួមរបស់សង្កាត់ប្រចាំឆ្នាំនីមួយៗត្រូវអនុវត្តតាមគោលការណ៍ដែលចែងក្នុងសៀវភៅណែនាំ ស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានចែងថា «ទុនចូលរួមរបស់មូលដ្ឋាន គឺជាការចូលរួមចំណែកដោយស្ម័គ្រចិត្ត ហើយមិនមែនជាកាតព្វកិច្ចផ្លូវច្បាប់ទៅលើរូបវន្តបុគ្គលណាមួយនោះទេ» និង រហូតដល់មានការណែនាំថ្មីរបស់ក្រសួងមហាផ្ទៃ។

ការកំណត់ខាងលើនេះ ដើម្បីសម្រួលដល់ការអនុវត្ត និងជម្រុញឱ្យក្រុមប្រឹក្សាសង្កាត់ មានការទទួលខុសត្រូវដោយខ្លួនឯង ក្នុងការពង្រឹងភាពម្ចាស់ការរបស់ប្រជាពលរដ្ឋ និងការចូលរួមរបស់មូលដ្ឋាន ដើម្បីរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកអភិបាលខណ្ឌ ចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកអភិបាលខណ្ឌទាំង ៩ ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

**<u>ចម្លងជូន:</u>**

- រតនាគាររាជធានីភ្នំពេញ
- សង្កាត់ទាំង ៩៦ *«ដើម្បីមុខការ»*
- ឯកសារ /កាលប្បវត្តិ

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤

www.phnompenh.gov.kh; Email : info@phnompenh.gov.kh